# រឿង គ្រូពេទ្យភូមិយើង

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរខាងក្រោម ។



នៅវេលាយប់មួយ ជីដូនខ្ញុំគ្រុនក្តៅខ្លាំង រហូតដល់សន្លប់បាត់ស្មារតី ។ ម្តាយខ្ញុំភ័យស្លន់ស្លោមិនដឹងជាធ្វើដូចម្តេច ។ មួយសន្ទុះក្រោយមក គាត់ក៏សម្រេចចិត្តជូនលោកយាយទៅមណ្ឌលសុខភាព ។ អ្នកជិតខាងបានឮសំឡេងជជែកគ្នា ក៏បើកទ្វារចេញមកមើល ។ អ្នកខ្លះជួយកោសរឹត ខ្លះទៅហៅរ៉ឺម៉កមកដឹកលោកយាយ ។ ពូប្រធានភូមិបានដឹងរឿងក៏ប្រញាប់មកជួយគ្រាហ៍លោកយាយ ហើយធ្វើដំណើរទៅជាមួយគ្រួសារខ្ញុំដែរ ។

ពេលទៅដល់មណ្ឌលសុខភាព លោកគ្រូពេទ្យវ័យក្មេងម្នាក់ដែលប្រចាំការ បានចេញមកសាកសួរ ដោយរាក់ទាក់បំផុត ។ យើងនាំគ្នាជួយគ្រាហ៍ លោកយាយចូលក្នុងបន្ទប់ ។ លោកគ្រូពេទ្យ ចាប់ផ្តើមពិនិត្យជំងឺលោកយាយ ដោយយកចិត្តទុកដាក់ ។ បន្ទាប់មក លោកចាក់ថ្នាំជូនលោកយាយ ហើយប្រាប់ម្តាយខ្ញុំកុំឱ្យបារម្ភ ព្រោះបន្តិចទៀតលោកយាយនឹងធូរស្រាលហើយ ។ លោកយកថ្នាំមកទុកជូនលោកយាយពិសា នៅពេលគាត់ដឹងខ្លួនហើយក៏ហួសទៅសម្រាក ។ មួយសន្ទុះក្រោយមក គាត់អញ្ជើញមកម្តងទៀត ឃើញលោកយាយដឹងខ្លួន លោកនិយាយលួងលោមដោយសម្តីផ្អែមល្ហែម គួរឱ្យកក់ក្តៅ ។





ពេលលោកយាយបានធូរស្រាល ពូប្រធានភូមិក៏លាពួកយើងត្រឡប់ទៅផ្ទះវិញ ។ យើងនាំគ្នាសម្រាកនៅទីនោះមួយយប់ ។ លុះព្រឹកឡើង យើងនាំគ្នាអរគុណលោកគ្រូពេទ្យ ហើយនាំលោកយាយត្រឡប់មកផ្ទះវិញ ។

## សំណួរ

១. តើរឿងនេះ មានតួអង្គណាខ្លះ ?

២. តើអ្នកណាជាតួអង្គឯក ? អ្នកណាជាតួអង្គរង ?

៣. តើរឿងនេះ កើតឡើងនៅកន្លែងណា ? នៅពេលណា ?

## លំហាត់

ក. **ចូរជ្រើសរើសចម្លើយ ដែលជាព្រឹត្តិការណ៍នៃរឿង ។**

១. ជីដូនខ្ញុំគ្រុនក្តៅខ្លាំង រហូតដល់សន្លប់បាត់ស្មារតី ។

២. គ្រូពេទ្យមិនអើពើ នឹងជំងឺរបស់លោកយាយឡើយ ។

៣. អ្នកជិតខាងភ័យស្លន់ស្លោ នឹងជំងឺលោកយាយ ។

៤. ប្រធានភូមិខ្ទះខ្ទែង ជូនលោកយាយទៅមណ្ឌលសុខភាព ។

៥. គ្រូពេទ្យពិនិត្យព្យាបាល លោកយាយរហូតជាសះស្បើយ ។

ខ. **ចូររកពាក្យមានន័យផ្ទុយនឹងពាក្យខាងក្រោម ។**

| ធូរ | ផ្អែមល្ហែម | ក្មេង |
|---|---|---|
| ១. លំបាក | ១. បូបាច់ | ១. ចាស់ |
| ២. តឹង | ២. ពីរោះ | ២. ខ្ចី |
| ៣. រលុង | ៣. គំរោះគំរើយ | ៣. ទុំ |

គ. **ចូររកពាក្យមានសូរដូចនឹងពាក្យ"លា សួរ"ដោយពន្យល់ន័យនៃពាក្យនីមួយៗផង ។**